**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់រមណីយដ្ឋានប្រាសាទបេងមាលា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ ០០១នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ " អប្សរា "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើតអាជ្ញាធរ " អប្សរា "
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤

## សំ រេ ច

## ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានប្រាសាទបេងមាលា ជាតំបន់ការពារស្ថិតនៅក្នុងភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ផ្អែកទៅតាមព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប អង្គរ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានបំណង :

-អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិសាស្ត្រ និងលើកតម្លៃពន្ធុរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត

-អភិរក្សទេសភាព វប្បធម៌ និងអភិវឌ្ឍតំបន់ទេសចរណ៍

-ការពារបរិស្ថានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង និងអនុវត្តតាមគោលការណ៍នានាដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

## ជំពូកទី ២

### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យមានការត្រួតពិនិត្យ រាល់ការអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋានការពារដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទបេងមាលា កំណត់ជាពីរតំបន់ផ្សេងគ្នា ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ហើយត្រូវទទួលកិច្ចការពារខុសៗគ្នា :

ក.តំបន់ ១ : រមណីយដ្ឋានមានប្រាសាទ គឺជាតំបន់ដែលមានស្ថានីយបុរាណវត្ថុសំខាន់ៗជាងគេ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។ តំបន់នេះ មានចម្ងាយប្រវែង១៥០ម៉ែ (មួយរយហាសិបម៉ែត្រ) ពីកំពែងប្រាសាទក្រៅបំផុត ដល់ខ្សែបន្ទាត់និយាមកានៃចំណុចដូចតទៅ :

| | | |
|---|---|---|
| A0 (416080 ; 1489350) | , | A6 (419150 ; 1489550) |
| A1 (416140 ; 1490400) | , | A7 (418360 ; 1489520) |
| A2 (417260 ; 1490400) | , | A8 (417570 ; 1489500) |
| A3 (417260 ; 1490470) | , | A9 (417200 ; 1489490) |
| A4 (419300 ; 1490470) | , | A10 (417130 ; 1489360) |
| A5 (419300 ; 1489560) | , | A11 (416560 ; 1489370) |

តំបន់ទី ១នេះ មានផ្ទៃក្រឡា ៣១៥ ហ.ត ៣ ( បីរយដប់ប្រាំហិតា និងបីអារ )

ខ.តំបន់ ២ : ឧទ្យានបុរាណវត្ថុត្រូវការពារ គឺតំបន់ដែលសម្បូរសំណល់បុរាណវត្ថុដែលត្រូវការពារទប់ទល់នឹងការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍន៍មិនសមស្រប និងត្រូវមានការវាយតម្លៃផលប៉ះពាល់ដល់បរិស្ថាន ។ តំបន់នេះមានចម្ងាយប្រវែង ២៥០ម៉ែ ( ពីររយហាសិបម៉ែត្រ ) ពីខ្សែបន្ទាត់និយាមកា A0........A11 ដល់ខ្សែបន្ទាត់និយាមកានៃចំណុចដូចតទៅ :

| | | |
|---|---|---|
| B0 (415770 ; 1489130) | , | B4 (419550 ; 1490700) |
| B1 (415770 ; 1490650) | , | B5 (419550 ; 1489310) |
| B2 (417030 ; 1490630) | , | B6 (417350 ; 1489250) |
| B3 (417030 ; 1490710) | , | B7 (417300 ; 1489120) |

តំបន់ទី ២ នេះមានផ្ទៃក្រឡា ២៤១ ហត ៦ (ពីររយសែសិបមួយហិតា និងប្រាំមួយអារ)

ចំពោះតំបន់ទី ៣ តំបន់ទី ៤ និងតំបន់ទី ៥ កិច្ចការពារមានចែងនៅក្នុងព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ ។

## ជំពូកទី ៣

## ការកែប្រែតំបន់

**មាត្រា ៥.-**

តំបន់នីមួយៗត្រូវបានគ្រប់គ្រង ថែទាំ និង ការពារស្របតាមទិសដៅសំរាប់តំបន់ត្រូវការពារសៀមរាបអង្គរ ។ បរិវេណ និងរាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទបេងមាលា អាចត្រួតពិនិត្យឡើងវិញ ហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែងដើម្បីធានារាល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តភាពដូចមានចែងក្នុង មាត្រា ៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៤ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ


ZONE DE PROTECTION
Projet: PROPOSITION DE ZONAGE DE BENG MEALEA
PLAN DE ZONAGES
AUTORITE APSARA
DEPARTEMENT DES MONUMENTS
ET DE L'ARCHEOLOGIE
ZONE 1
ZONE 2
400.8
442.5